

# ដំណោះស្រាយ របស់ លោក សុខ-ទូច

លោក សុខ-ទូច ប្រធាន ក្រុមការងារស្រាវជ្រាវ នៃរាជបណ្ឌិតសភាខ្មែរ ស្នើរឲធ្វើវិសោធនកម្ម មាត្រាទី២ នៃរដ្ឋធម្មនុញ្ញ ជាចាំបាច់ ដើម្បីអាចនឹង ដោះស្រាយ បញ្ហាព្រំដែន ខ្មែរ-យៀកណាម ក្នុងករណី ដែល អ.ស.ប. និង មហាអំណាច នៃបស្ចឹមប្រទេស មិនអាចរកឃើញ ផែនទី ដែល សម្តេច សីហនុ ផ្ញើរជូន នៅក្នុងឆ្នាំ ១៩៦៤ ដល់គេ ដើម្បី ទុកជាផែនទីជាផ្លូវការ របស់ រាជាណាចក្រកម្ពុជា។ អនុសាសន៍ របស់ លោក សុខ-ទូច មាន៥ ចំណុចៈ

ទី១/ សូមឲភាគីពាក់ព័ន្ធ រក្សាឯកភាពជាតិ ក្នុងការចរចា ដោះស្រាយបញ្ហាព្រំដែន ;

ទី២/ ក្រោយបោះបង្គោលព្រំដែន រដ្ឋាភិបាលគប្បីយកលទ្ធផលទៅសុំការយល់ព្រមពីអង្គនីតិបញ្ញាត្តិ ;

ទី៣/ ប្រសិនមានការរាំងស្ទះណាមួយ ពីការប្រើប្រាស់ផែនទី ដែលមិនឆ្លើយតបនឹង រដ្ឋធម្មនុញ្ញ គប្បីធ្វើវិសោធនកម្ម មាត្រាទី២ នៃរដ្ឋធម្មនុញ្ញ ;

ទី៤/ គួរប្រែដំបន់ព្រំដែនទៅជា កន្លែង អភិវឌ្ឍន៍ ;

ទី៥/ ការដោះស្រាយបញ្ហាព្រំដែន ត្រូវផ្អែកគោលសន្តិភាព សហវិជ្ជមាន ដោយស្របច្បាប់ជាតិ និង ច្បាប់ អន្តរជាតិ។

បើយើង យក អនុសាសន៍ លោក សុខ-ទូច មកពិនិត្យមើល យើងមានការចាប់អារម្មណ៍ភ្លាមៗ ថា អនុសាសន៍ នេះ គ្មាន គំណ (articulation) នៃគំនិត ជាដំណោះស្រាយ នោះឡើយ តែគ្រាន់តែជា ការប្រកាស នៃគោលការណ៍ ជាធម្មតា គឺ រក្សាសាមគ្គីភាពជាតិ, គោលសន្តិភាព និង គោរពច្បាប់ជាតិ និង អន្តរជាតិ។

តែនៅក្នុង អនុសាសន៍ នេះ មានចំណុចពីរ ទី២ និង ទី៤ ដែលនាំឲយើងមានអំពល់ព្រោះជា អនុសាសន៍ គ្មានសមហេតុផលទាល់តែសោះៈ

ទី២ៈ ក្រោយបោះបង្គោលព្រំដែនហើយ ព្រំដែន វាក្លាយជាព្រំដែន ជាផ្លូវការ ជាស្ថាពរ រវាង ខ្មែរ នឹង យៀកណាម រួចស្រេចទៅហើយ ចុះហេតុអ្វី លោក សុខ-ទូច ស្នើថា គប្បីយកលទ្ធផលទៅសុំការយល់ព្រមពីអង្គនីតិបញ្ញាត្តិ។ ចុះបើ អង្គនីតិបញ្ញាត្តិ មិនយល់ព្រមតើកម្ពុជាត្រូវដោះស្រាយជាមួយយៀកណាម បែបណា បើ រដ្ឋាភិបាលទាំងពីរ យល់ព្រមនឹងគ្នាបោះបង្គោល រួចស្រេចទៅហើយ។ ដូច្នេះ សំណើរ លោក សុខ-ទូច នេះ បញ្ជាក់ឲឃើញថាលោក សុខ-ទូច គាត់គ្មាន សញ្ញាណ នៃច្បាប់ និង នយោបាយ បន្តិចសោះ

ឱប សៅ សង្ហា
២៣ កក្កដា ២០១៥

ឡើយដែលនាំឲយើង មានការសង្ស័យ ទៅលើតម្លៃ នៃបណ្ឌិតសភាកម្ពុជា ដែលមានលោក សុខ-ទូច ជា សមាជិក ព្រោះវាមិនដែល មានសោះ ក្នុងប្រទេស ដែលមាននីតិរដ្ឋ អង្គនីតិប្រតិបត្តិ ធ្វើអ្វីមួយរួចហើយ ទើបយកទៅសុំ ការយល់ព្រមពី អង្គនីតិបញ្ញត្តិ។

ទី៤៖ គួរប្រែដំបន់ព្រំដែនទៅជា កន្លែង អភិវឌ្ឍន៍៖ ដំបន់ ព្រំដែន ខ្មែរ-យៀកណាម បច្ចុប្បន្ននេះ បើប្រែជាកន្លែង អភិវឌ្ឍន៍ គឺ ច្បាស់ជា ប្រគល់ឲក្រុមហ៊ុន យៀកណាម គេចូលមកធ្វើអភិវឌ្ឍន៍ ជាផ្លូវការតែម្តង ដូចសព្វថ្ងៃ យួនគេចូល មកធ្វើអភិវឌ្ឍន៍ រួចស្រេចទៅហើយ នៅក្នុងដំបន់ «ស» ឬ ដំបន់ ដែល លោក វ៉ា-គីមហុង គាត់ថា នៅមានទំនាស់ជាមួយ យៀកណាម និងនៅ គ្រប់ខេត្តខ្មែរ ជាប់នឹង ព្រំប្រទល់ យៀកណាម។ ដូច្នេះសំណើរនេះ គឺ លោក សុខ-ទូច គាត់ស្នើ ដើម្បីតម្រូវចិត្ត យៀកណាម ផង និងហ៊ុន-សែន ផង ព្រោះ លោក ហ៊ុន-សែន គាត់ ក៏ធ្លាប់និយាយដែរថា គាត់សង់ «កាស៊ីណូ» តាមព្រំដែន ដើម្បីធ្វើជារបង ការពារ ទល់ដែន។ ម្យ៉ាងមួយទៀត ដំបន់ អភិវឌ្ឍន៍ មិនមែនចេះតែជ្រើសរើស ដើម្បីបំរើ ប្រយោជន៍ នយោបាយនោះឡើយ ព្រោះច្បាប់សេដ្ឋកិច្ច វាមាន សនិទានភាព (rationalité) និង ទំនង (logique) របស់វា មិនដូច លោក សុខ-ទូច គាត់ចង់បំរើនយោបាយ ចេះតែនិយាយ ដើម្បីអោយ យួន និង ហ៊ុន-សែន ញ តែប៉ុណ្ណោះទេ។

បញ្ហា ព្រំដែន ខ្មែរ-យៀកណាម មិនមែន ជាបញ្ហា ខ្មែរ នឹង ខ្មែរ នោះទេ គឺ វាជាបញ្ហា ខ្មែរ នឹង យៀកណាម បើ ហ៊ុន-សែន យល់ច្រឡំ គឺ គាត់ច្បាស់ជាបន្តចាប់ខ្មែរ ដាក់គុកព្រៃស និង សម្លាប់ ខ្មែរគ្នាឯង ដើម្បីការពារ ប្រយោជន៍ យួន តែប៉ុណ្ណោះ។ រឿងលោក ហ៊ុន-សែន បញ្ហា កងទ័ពគាត់ ទៅបោះទីនៅ ព្រំប្រទល់ ខ្មែរ-យៀកណាម សូមខ្មែរកុំយល់ច្រឡំឲសោះថា ទៅការពារបូរណភាពទឹកដីខ្មែរ  តាមពិត គឺ សំរាប់ធ្វើសង្គ្រាមប្រឆាំងនឹងខ្មែរណា ដែលនៅបន្ត តវ៉ា តាម វិធីអហឹង្សា ព្រោះនៅក្នុង ទំនងចិត្ត របស់ ហ៊ុន-សែន គឺប្រើកម្លាំងបាយដើម្បីបង្ក្រាបខ្មែរជានិច្ច។ កម្លាំងបាយនោះ គឺ សម្លុតខ្មែរ នឹងពាក្យសង្គ្រាមជានិច្ច។ ឧទាហរណ៍ បើ ហ៊ុន-សែន ចាញ់ឆ្នោត ក៏គាត់បង្កើត សង្គ្រាម។ យើងចង់សួរ លោក ហ៊ុន-សែន ថា គាត់ធ្វើសង្គ្រាម ជាមួយអ្នកណា ជាមួយ រាស្ត្រខ្មែរ ? រាស្ត្រខ្មែរ មានអ្វីនឹងធ្វើ សង្គ្រាមកើត បើ គាត់ ក្រលំបាក ស្ទើរ រកបាយស៊ី មិនបានផង។ ដូច្នេះ ទ័ពហ៊ុន-សែន លើកទៅកាន់ព្រំដែន ខ្មែរ-យៀកណាម គឺ ដើម្បីការពារយួនទៅវិញទេ គឺដើម្បី ធានាសន្តិសុខ ឲយួន ចូលមកធ្វើ អភិវឌ្ឍន៍ នៅក្នុងទឹកដីខ្មែរ។

ដូច្នេះ អនុសាសន៍ លោក សុខ-ទូច គ្រាន់តែជាតន្ត្រី ហួសសម័យ សំរាប់ តែកំដរនយោបាយ របស់ លោក ហ៊ុន-សែន តែប៉ុណ្ណោះ។

ឧប សៅ សង្ហា
២៣ កក្កដា ២០១៥